**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារជូនពរ

## ផ្ញើជូន
## នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ
## ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល២០២៣

**មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហាន គ្រប់ស្ថាប័ន កងឯកភាព នៃកងយោធពលខេមរភូមិន្ទទាំងអស់ ជាទីស្នេហា !**

ក្នុងឱកាសដ៏វិសេសវិសាល ប្រកបដោយសេចក្តីសោមនស្សរីករាយ ក្នុងទិវាចូលឆ្នាំថ្មី ឆ្នាំសកល២០២៣ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នៃកងយោធពលខេមរភូមិន្ទ និងក្នុងនាមខ្ញុំផ្ទាល់ សូមផ្ញើជូននូវការសាកសួរសុខទុក្ខ ដោយក្តីនឹករលឹកនិងជាទីស្រឡាញ់រាប់អានយ៉ាងជ្រាលជ្រៅបំផុត ចំពោះមេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ ក្នុងកងយោធពលខេមរភូមិន្ទ ដែលកំពុងបំពេញភារកិច្ចនៅតាមស្ថាប័ន កងឯកភាពនានា ក៏ដូចជាសិក្ខាកាមកំពុងសិក្សាជំនាញផ្សេងៗទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ព្រមទាំងកងកម្លាំងបំពេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ សូមជូននូវសព្ទសាធុការពរជ័យសិរីមង្គល វិបុលសុខ ទទួលបាននូវសុខភាពល្អ កម្លាំងពលំមាំមួនចៀសផុតអំពីជំងឺផ្សេងៗគ្រប់យ៉ាង និងសម្រេចបានជោគជ័យនូវភារកិច្ចថ្មីៗទទួលបានកិត្តិយសកេរ្តិ៍ឈ្មោះជូនជាតិមាតុភូមិនៃយើង។

នាឱកាសនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរយ៉ាងស្មោះចំពោះជោគជ័យដ៏ត្រចះត្រចង់នូវសមិទ្ធផលដ៏ធំធេងក្នុងឆ្នាំកន្លងមក ដែលកងយោធពលខេមរភូមិន្ទយើងសម្រេចបាន គឺកើតចេញពីការលះបង់និងការខិតខំពុះពារជម្នះគ្រប់ឧបសគ្គនិងការលំបាក ធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីការពារជាតិមាតុភូមិ ការពារសន្តិសុខជាតិ ថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ និងភាពសុខក្សេមក្សាន្តរបស់ប្រជាជន។ ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះកងយោធពលខេមរភូមិន្ទ ដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងប្រតិបត្តិការសង្គ្រោះគ្រោះមហន្តរាយ និងជំនួយមនុស្សធម៌ផ្សេងៗ ជាពិសេសនៅក្នុងបរិបទនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ កងទ័ពត្រូវបានចាត់ទុកជាកម្លាំងនាំមុខក្នុងយុទ្ធនាការចាក់វ៉ាក់សាំងនៅទូទាំងប្រទេសដែលជាមោទនភាពខ្ពស់បំផុត ក្នុងការសង្គ្រោះអាយុជីវិតរបស់ប្រជាពលរដ្ឋពីការឆ្លងរីករាលដាលនៃជំងឺដ៏កាចសាហាវនេះ ក៏ដូចជាការចូលរួមដោះស្រាយបញ្ហាសុខភាពសកលលោកនៅក្នុងសង្គមជាតិផងដែរ។ ម្យ៉ាងទៀតកងយោធពលខេមរភូមិន្ទយើងបានចូលរួមអនុវត្តប្រកដោយជោគជ័យនូវភារកិច្ចអន្តរជាតិលើវិស័យមនុស្សធម៌សកលលោក បំពេញបេសកកម្មជាកងកម្លាំងរក្សាសន្តិភាពក្រោមឆត្ររបស់អង្គការសហប្រជាជាតិ ដើម្បីបុព្វហេតុសន្តិភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិល្អ ដែលជាមោទនភាព និងជាកិត្តិយសដ៏ខ្ពង់ខ្ពស់ឧត្តុង្គឧត្តមយ៉ាងក្រៃលែងរបស់កងយោធពលខេមរភូមិន្ទ ក៏ដូចជាប្រជាជាតិកម្ពុជាយើងទាំងមូលធ្វើឱ្យកិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជាកាន់តែល្បីរន្ទឺនៅលើឆាកអន្តរជាតិ។

សរុបមកវិញ រាល់សមិទ្ធផលដ៏ធំធេងដែលសម្រេចបានកន្លងមកនេះ គឺអាស្រ័យដោយការខិតខំប្រឹងប្រែងតស៊ូលះបង់ពុំខ្លាចនឿយហត់ និងការធ្វើពលិកម្មគ្រប់បែបយ៉ាងគួបផ្សំជាមួយនិងស្មារតីទទួលខុសត្រូវខ្ពស់ របស់ថ្នាក់ដឹកនាំគ្រប់ស្ថាប័ន កងឯកភាព ក្នុងការចាត់តាំងអនុវត្តការងារជាក់ស្តែងទៅតាមជំនាញ និងតួនាទីរៀងៗខ្លួន។

**មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ ក្នុងកងយោធពលខេមរភូមិន្ទ ជាទីស្នេហា!**

ជាថ្មីម្តងទៀត ក្នុងទិវាចូលឆ្នាំថ្មីឆ្នាំសកលនេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងក្នុងនាមខ្ញុំផ្ទាល់ សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតារក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមជួយប្រោះព្រំសព្វសាធុការពរជ័យ សិរីមង្គល ជូនចំពោះមេបញ្ជាការ មេបញ្ជាការរង គ្រប់ស្ថាប័ន កងឯកភាព និងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ ក្នុងកងយោធពលខេមរភូមិន្ទ ព្រមទាំងសិក្ខាកាមទាំងអស់ដែលកំពុងបំពេញការសិក្សាជំនាញផ្សេងៗ នៅតាមបណ្តាប្រទេសជាមិត្ត រួមទាំងកងកម្លាំងបំពេញបេសកកម្មរក្សាសន្តិភាព ក្រោមកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់អង្គការសហប្រជាជាតិ នឹងក្រុមគ្រួសារទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងកាយមាំមួនខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ អាយុយឺនយូរ និងសម្រេចបានជោគជ័យគ្រប់ភារកិច្ច ជូនជាតិមាតុភូមិ។

សូមផ្ញើជូននូវការសួរសុខទុក្ខ និងជូនពរដល់យោធិន **ជំងឺ របួស ពិការ** ដែលកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យនានា សូមឱ្យឆាប់ជាសះស្បើយពីជំងឺ មានសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួន និងប្រកបដោយសេចក្តីសុខគ្រប់ពេលវេលា និងសូមជូនពរដល់អតីតយុទ្ធជន ព្រមទាំងក្រុមគ្រួសារដែលកំពុងរស់នៅក្នុងសង្គមស៊ីវិល សូមមានជីវភាពរស់នៅបានធូរធា និងប្រកបដោយសុភមង្គលរុងរឿងជានិច្ច។ ជាពិសេសត្រូវបន្តប្រកាន់ខ្ជាប់នូវការណែនាំរបស់រាជរដ្ឋាភិបាល និងវិធានការការពារនានារបស់ក្រសួងសុខាភិបាល គឺត្រូវពាក់ម៉ាស់ លាងដៃជាមួយសាប៊ូ អាកុល ឬជែល រក្សាគម្លាតសុវត្ថិភាព ដើម្បីបង្ការទប់ស្កាត់ និងការពារឱ្យរួចផុតពីគ្រោះនៃការឆ្លងពីជំងឺកាចសាហាវផ្សេងៗព្រមទាំងទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** ជានិច្ចនិរន្តរ៍តរៀងទៅ។

ថ្ងៃ[illegible] ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ៤ ឆ្នាំ២០២២
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**